# រឿង បុរសបាញ់ទង់

---

មាននិទានមួយដំណាលថា : នៅស្រុកមួយនោះ មានបុរស ២ នាក់ ម្នាក់ឈ្មោះចៅសោកែ ម្នាក់ទៀតឈ្មោះចៅពាលោ ។ ទៅរករៀនមន្តអាគមចេះសព្វគ្រប់ ហើយតែងរកឧបាយកលចំហូវយកទ្រព្យរបស់គេមកជារបស់ខ្លួន ។

ថ្ងៃមួយចៅសោកែចេញទៅបាញ់ទុងបានមួយ ។ ចៅពាលោគិតថា " សោកែគាត់នឹងឲ្យសាច់ទុងអញស៊ីផងឬទេ ? បើគាត់មិនឲ្យសាច់ទុងអញស៊ីទេ អញនឹងរករឿងគាត់ឲ្យកើតជាក្តីឡើងបានម្តង " ។ ឯចៅសោកែស្លអាំងសាច់ទុងរួចស្រេចក៏បរិភោគទៅ ពុំបានឲ្យទៅចៅពាលោឡើយ ។ ចៅពាលោក៏ប្តឹងទៅចៅក្រម ឲ្យកោះចៅសោកែ យកទៅជំនុំជម្រះ ហើយចៅពាលោប្តឹងចៅក្រមនោះថា "កាលឪពុកខ្ញុំព្រះបាទឈឺថ្កាត់នោះ គាត់ផ្តាំនឹងខ្ញុំព្រះបាទថា "បើគាត់ស្លាប់ទៅនឹងទៅយកកំណើតជាសត្វទុង ដោយជួរចំបួរមេបារៀង ៗ មក សឹងស្លាប់ទៅកើតជាទុងទាំងអស់ បើមានអ្នកណាមួយទៅបាញ់ទុង ឲ្យប្តឹងចៅក្រមឲ្យចាប់យកទៅជំនុំពិចារណាលក់ពិន័យ តាមដោយនូវច្បាប់ស្លាប់គេ ឥឡូវនេះ ចៅសោកែសម្លាប់ឪពុកខ្ញុំស៊ី ហេតុនេះសូមព្រះបាទម្ចាស់កាត់សេចក្តីឲ្យទានខ្ញុំព្រះបាទហោង " ។

ឯចៅសោកែឆ្លើយដោះសារថា "ឪពុកម្តាយខ្ញុំប្រាប់រៀង ៗមកថា " មេបាជីដូនជីតាឪពុកម្តាយ អម្បាលដែលស្លាប់ទៅសឹងយកកំណើតជាត្រី ហើយផ្តាំថា បើមានសារពើសត្វអ្វីទៅសម្លាប់សត្វត្រីស៊ី ឲ្យខ្ញុំប្របាទបាញ់សម្លាប់សត្វអស់នោះស៊ីវិញ បើសត្វអស់នោះមានកូនចៅផៅពង្សនៅជាមនុស្ស ឲ្យប្តឹងចៅក្រមឲ្យចាប់យកមកជំនុំជម្រះលក់ពិន័យកូនចៅផៅពង្សអស់នោះ ឥឡូវនេះ ហ្វូងទង់នាំគ្នាទៅប្លន់ចាប់ត្រីជាជីដូនជីតាឪពុកម្តាយខ្ញុំប្របាទស៊ី ទើបខ្ញុំប្របាទបាញ់ទុងអស់នោះ, ឥឡូវបើចៅពាលោថាទុងនោះជាឪពុកគេដូច្នេះ សូមអស់លោកជាចៅក្រមជំនុំជម្រះ ពិចារណាសេចក្តីនេះឲ្យទានខ្ញុំប្របាទចុះ " ។

ចៅក្រមជំនុំពិចារណាសេចក្តីនេះមិនដាច់ស្រេច ទើបនាំចៅទាំង ២ នាក់ ឡើងទៅក្រាបបង្គំទូលព្រះមហាក្សត្រតាមដំណើរសេចក្តីនោះសព្វគ្រប់ប្រការ ។ ចៅពាលោឃើញថាក្តីរបស់ខ្លួនចាញ់ប្រៀបក្តីរបស់ចៅសោកែ ទើបនិយាយដោះសាខ្លួនថា " ចៅសោកែពុំបានបាញ់ទុងនៅអាយឡើយបាញ់ទុងពីនាយទេ ខ្ញុំព្រះបាទអម្ចាស់ប្រកាន់ត្រង់នេះឯង " ។

ព្រះមហាក្សត្រ មានព្រះបន្ទូលដណ្តឹងសួរទៅចៅពាលោថា " ឯទុងឪពុកចៅនៅឯអាយស៊ីអ្វី ស៊ីក្តាមខ្យងឬស៊ីត្រី ? " ។ ចៅពាលោក្រាបទូលថា " ស៊ីត្រី " ។ ព្រះមហាក្សត្រមានព្រះបន្ទូលថា " បើដូច្នេះទុងជាឪពុកឯងចាប់ត្រីជាឪពុកចៅសោកែស៊ី ដូចពាក្យចៅសោកែមែន " ហើយទ្រង់បង្គាប់ឲ្យចៅពាលោទៅជាខ្ញុំចៅសោកែ ។ ចៅទាំង ២ ក៏សុខចិត្តហើយក្រាបថ្វាយបង្គំលាត្រលប់ទៅកាន់លំនៅអាត្មាវិញហោង ។